UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ថ្លែងថា " ការប្រើប្រាស់ និងការរំលោភនៃបណ្តឹងបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពក្នុងការសំដែងមតិយោបល់ដែលរដ្ឋធម្មនុញ្ញធានាការពារ និងការអភិវឌ្ឍន៍លិទ្ធិប្រជាធិបតេយ្យ "

# កំណត់សង្ខេបអំពីសេរីភាពក្នុងការសំដែងមតិ ការបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩

ចាប់តាំងពីខែមេសាឆ្នាំនេះមក មានបណ្តឹងព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នា មិនតិចជាងប្រាំបីទេ ពីបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិត ត្រូវបានប្តឹងទៅតុលាការនានាដោយអាជ្ញាធរសាធារណៈជាន់ខ្ពស់មួយចំនួនរបស់រដ្ឋាភិបាល ប្រឆាំងនឹងការរិះគន់រដ្ឋាភិបាល ។ បណ្តឹងមួយក្នុងចំណោមនោះ មិនត្រូវបានប្តឹងដោយបុគ្គលដែលអះអាងថាកើតទុក្ខមិនសុខនោះឡើយ ផ្ទុយទៅវិញ បណ្តឹងនោះត្រូវបានធ្វើឡើងជាលក្ខណៈទូទៅមួយក្នុងនាម " រដ្ឋាភិបាល " ។ បច្ចុប្បន្ន ករណីទាំងនេះកំពុងស្ថិតក្នុងការស៊ើបអង្កេតដោយលោក សុខ រឿន ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ ។ ករណីមួយក្នុងចំណោមនោះ ត្រូវបានជំនុំជម្រះនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ (សូមមើលឧបសម្ព័ន្ធសំរាប់ជាសេចក្តីលំអិតនៃករណីទាំងនេះ) ។

ការកើនឡើងថ្មីៗនេះក្នុងការប្រើប្រាស់បណ្តឹងព្រហ្មទណ្ឌពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិតដែលភាគច្រើនបានប្តឹងប្រឆាំងនឹងអ្នកនយោបាយ អ្នកសារព័ត៌មាន និងអ្នកឯទៀតដែលសំដែងមតិរបស់ខ្លួនដោយសន្តិវិធីអំពីបញ្ហាទាំងឡាយដើម្បីផលប្រយោជន៍សាធារណៈ បានគំរាមរារាំងនូវអ្វីដែលពួកគេអាចជជែកពិភាក្សា និងផ្លាស់ប្តូរមតិយោបល់គ្នាអំពីបញ្ហាទាំងនេះបានដោយសេរីនោះ។ ទង្វើទាំងនេះ ធ្វើឲ្យប៉ះពាល់ដល់សេរីភាពក្នុងការសំដែងមតិយោបល់ដែលរដ្ឋធម្មនុញ្ញធានាការពារ ហើយដែលជាមូលដ្ឋានគ្រឹះសំរាប់ការអនុវត្តន៍សិទ្ធិពលរដ្ឋ និង

សិទ្ធិនយោបាយ។ ការអនុវត្តន៍សិទ្ធិនេះ គឺជាការវាស់ស្ទង់មួយដ៏សំខាន់អំពីកំរិតនៃការការពារ និងការគោរពសិទ្ធិ មនុស្សទាំងអស់ឯទៀតនៅក្នុងសង្គមផ្សេងៗ ។ គ្មានជនណាម្នាក់ត្រូវភ័យខ្លាចក្នុងការសំដែងមតិរបស់ ខ្លួនដោយសន្តិវិធីនោះទេ ឲ្យតែវាមិនបំពានលើសិទ្ធិរបស់អ្នកដទៃ ។ ការបំបិទសិទ្ធិសេរីភាពក្នុងការ សំដែងមតិយោបល់ តាមរយៈការប្រើប្រាស់ ឬការគំរាមចាត់វិធានការតាមផ្លូវច្បាប់ ទោះជាបណ្តឹង នោះជាបណ្តឹងរដ្ឋប្បវេណី ឬជាបណ្តឹងព្រហ្មទណ្ឌក្តី ជាពិសេសក្នុងបរិបទមួយដែលតុលាការងាយនឹងរងឥទ្ធិពលពីអំណាចនីតិប្រតិបត្តិ នោះគឺជាការគំរាមកំហែងធ្ងន់ធ្ងរមួយដល់ការអភិវឌ្ឍន៍នៃលិទ្ធិ ប្រជាធិបតេយ្យ ដែលអាចធ្វើឲ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងរយៈពេល ១៦ ឆ្នាំកន្លងមកនេះ ក្នុងការកសាងឡើងវិញនូវបរិយាកាសមួយដែលអត់ឱន និងពហុបក្សនៅកម្ពុជា ។ តាមបទពិសោធន៍ ពីប្រទេសនានា បង្ហាញថា ការដាក់កំរិតសេរីភាពក្នុងការសំដែងមតិជំនួសឲ្យការដោះស្រាយបញ្ហា និងការរិះគន់ តាមរយៈការពិភាក្សានិងការជជែកមួយសមហេតុផល មិនត្រឹមតែបង្កើតស្ងំយទិទៀន នោះទេ ប៉ុន្តែថែមទាំងបង្កឲ្យមានភាពភ័យខ្លាច ភាពអល់ឯកចិត្ត និងកំហឹងដែលជាហានិភ័យ នៃការឈានទៅរកជំលោះ និងអំពើហឹង្សាកាន់តែខ្លាំងឡើងថែមទៀត ។

ទន្ទឹមនឹងនេះ សេរីភាពក្នុងការសំដែងមតិយោបល់មិនមែនគ្មានដែនកំណត់នោះទេ។ សេរីភាពនេះ គួរតែបានប្រើប្រាស់ដោយសន្តិវិធី ដោយគោរពចំពោះអ្នកដទៃ និងទស្សនៈអ្នកដទៃ និងមិនបង្កឲ្យមានអំពើហឹង្សាឡើយ។ ច្បាប់អន្តរជាតិបញ្ជាក់ច្បាស់ អំពីតុល្យាភាពសមស្របរវាងសិទ្ធិក្នុងការសំដែងមតិយោបល់ និងការជជែកដោយសេរីអំពីបញ្ហាដែលជាផលប្រយោជន៍សាធារណៈ និងការការពារកិត្តិសព្ទរបស់បុគ្គល ។ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលជាផ្នែកមួយនៃច្បាប់កម្ពុជា ចែងថា ការរឹតត្បិតណាមួយលើសេរីភាពក្នុងការសំដែងមតិត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ ដើម្បីគោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ ឬការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ។

ក្រោមច្បាប់អន្តរជាតិ វាមិនគ្រប់គ្រាន់ទេដែលថា ការជជែកខាងនយោបាយអំពីបញ្ហាដែលជាផលប្រយោជន៍សាធារណៈ ត្រូវគេសម្តែងចេញជាពាក្យសំដីខ្លាំងៗ ឬត្រូវគេឃើញថាជាការមិនគោរព ឬផ្ទុយនឹងគោលនយោបាយរបស់រដ្ឋាភិបាល សំរាប់ការដាក់កំរិតលើការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការសំដែងមតិដែលស្របច្បាប់ ។ ការជជែកពិភាក្សាដោយចំហរ និងមិនភ័យខ្លាចអំពីបញ្ហា

ដែលជាផលប្រយោជន៍សាធារណៈ ជាផ្នែកមួយ និងជាកញ្ចប់នៃដំណើរការលិទ្ធិប្រជាធិបតេយ្យ ។ ក្រោមរដ្ឋធម្មនុញ្ញ រដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋរបស់ខ្លួន ចំពោះគោលនយោបាយ និងការអនុវត្តន៍ទាំងឡាយរបស់ខ្លួន ដូច្នេះសកម្មភាពទាំងនេះត្រូវតែបើកចំហរឲ្យមានការពិនិត្យពិច័យ ការរិះគន់ និងការជជែកដេញដោលជាសាធារណៈ ។ នៅជុំវិញពិភពលោកនេះមានការទទួលស្គាល់កាន់តែច្រើនឡើងៗថា ការជជែកខាងនយោបាយអំពីបញ្ហាដែលជាផលប្រយោជន៍សាធារណៈ ត្រូវតែបានការពារ ហើយថាច្បាប់រដ្ឋប្បវេណី ជាជាងច្បាប់ព្រហ្មទណ្ឌ គឺគ្រប់គ្រាន់សំរាប់ការពារបុគ្គល - ជាជាងរដ្ឋាភិបាល - កិត្តិសព្ទក្នុងករណីដ៏កម្របំផុតដែលករណីទាំងនេះត្រូវបានរំលោភបំពាន ដោយការជជែកដេញដោលខាងនយោបាយនោះ ។

នៅពេលធ្វើការស៊ើបអង្កេតបណ្តឹងដែលដាក់មកខ្លួន តុលាការក្រុងត្រូវតែស្ថិតក្រោមកាតព្វកិច្ចខាងផ្លូវច្បាប់ ក្នុងការអនុវត្តន៍បទដ្ឋានអន្តរជាតិទាំងនេះ និងធ្វើការវាស់ស្ទង់ករណីនីមួយៗទៅនឹងបទដ្ឋានទាំងនេះ ។

ចំពោះសមាជិករដ្ឋសភា ច្បាប់អន្តរជាតិទទួលស្គាល់តួនាទីដ៏ពិសេសដែលពួកគាត់មានក្នុងដំណើរការលិទ្ធិប្រជាធិបតេយ្យ និងក្នុងការរៀបចំឲ្យមានការសំដែងមតិ និងការជជែកដេញដោលជាសាធារណៈ ។ គោលបំណងសំខាន់នៃការផ្តល់អភ័យឯកសិទ្ធិសភានេះ គឺដើម្បីឲ្យសមាជិកសភាគ្រប់រូបអាចបំពេញភារកិច្ចរបស់ខ្លួនជាតំណាងរាស្ត្រ និងជាអ្នកធ្វើច្បាប់ដោយគ្មានការភ័យខ្លាចមានការសងសឹក ។ សភា ដូចដែលឈ្មោះនេះបញ្ជាក់ស្រាប់ គឺជាកន្លែងមួយក្នុងសង្គម ដែលបញ្ហាផ្សេងៗត្រូវបានពិភាក្សាដោះស្រាយ ។ ការដកអភ័យឯកសិទ្ធិសភា ឬការគំរាមដកអភ័យឯកសិទ្ធិសភាដោយគ្មានមូលហេតុសុពលក្រៅតែពីបំភិតបំភ័យសមាជិកសភា និងបំបិទការជជែកខាងនយោបាយ ឬការជជែកផ្សេងទៀត បង្ហាញពីការមិនគោរព និងការប្រមាថចំពោះការជជែកដោយចំហរ និងបែបប្រជាធិបតេយ្យ ។ គេគួរតែពិនិត្យពិចារណា ចំពោះតែករណីនៃអំពើល្មើសធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ ។

ការបន្តបណ្តឹងទាំងនេះ អាចធ្វើឲ្យដំណើរការអភិវឌ្ឍន៍នៃលិទ្ធិប្រជាធិបតេយ្យដែលផុយស្រួយដើរថយក្រោយ នៅកម្ពុជា ។ ការិយាល័យ OHCHR សូមរំលឹកឡើងវិញអំពីបទដ្ឋានអន្តរជាតិ ដែល

កម្ពុជាបានព្រមទទួលយក និងទំលាប់អនុវត្តន៍ដែលប្រសើរបំផុតក្នុងសហសម័យ ចំពោះជំលោះទាក់ទងនឹងការបរិហារកេរ្តិ៍ ៖

- ការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌចំពោះបញ្ហាសាធារណៈ ដែលបានលើកឡើងក្នុងករណីពាក់ព័ន្ធទាំងនេះ គឺជារឿងមួយហួសហេតុ និងមិនសមហេតុផល ។ ប្រសិនជាបុគ្គលណាមួយមិនយល់ស្របចំពោះការពិភាក្សាជាសាធារណៈ គេគួរតែឆ្លើយតបទៅនឹងខ្លឹមសារនៃការចោទប្រកាន់នោះ និងចូលរួមជជែកគ្នាវែកញែកយ៉ាងត្រឹមត្រូវអំពីបញ្ហាទាំងនោះ ជាមុនសិន ។ ប្រសិនជានៅតែមិនសុខចិត្តចំពោះពាក្យសំដីដែលនរណាម្នាក់បាននិយាយនោះ គេគួរតែប្តឹងទាមទារសំណងរដ្ឋប្បវេណី ជាជាង ដាក់បណ្តឹងព្រហ្មទណ្ឌ ដូចដែលច្បាប់កម្ពុជាបានចែង ។
- វាជាការសំខាន់សំរាប់ការការពារលំហរនៃលិទ្ធិប្រជាធិបតេយ្យសំរាប់ការជជែកដេញដោលជាសាធារណៈ ដែលអាជ្ញាធរសាធារណៈ អ្នកនយោបាយ ក៏ដូចជា សាធារណៈជន ដែលចូលរួមក្នុងការជជែកដេញដោលទាំងនេះ ត្រូវមានការអត់ធ្មត់ចំពោះទស្សនៈខ្វែងគំនិតគ្នានេះ ហើយមិនត្រូវចាត់ទុកទស្សនៈទាំងនេះថាជាការវាយប្រហារលើបុគ្គលឡើយ ។ មិនមានអ្វីខុសទេក្នុងការរិះគន់គោលនយោបាយសាធារណៈនោះ ។ នេះគឺជាផ្នែកមួយនៃបរិយាកាស និងដំណើការនៃលិទ្ធិប្រជាធិបតេយ្យមួយដែលល្អ ។
- វាមិនសមស្របទេសំរាប់ការដាក់ពាក្យបណ្តឹងក្នុងនាមរដ្ឋាភិបាលនោះ ។ ប្រសិនជាមន្ត្រីទាំងឡាយណាកើតទុក្ខមិនសុខចិត្ត តុលាការបើកចំហរឲ្យមន្ត្រីទាំងនោះដាក់ពាក្យបណ្តឹងក្នុងនាមបុគ្គល ។ ការអនុវត្តន៍នេះ ឆ្លុះបញ្ចាំងអំពីយុត្តិសាស្រ្តអន្តរជាតិលើបញ្ហានេះ និងការបកស្រាយមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ដោយគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ស្ថាប័នឃ្លាំមើលការអនុវត្តន៍កតិកាសញ្ញា ICCPR ដែលបានផ្តល់អនុសាសន៍ជំទាស់និងការដាក់ការបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ នៃរដ្ឋាភិបាល ។

- បញ្ហាទាំងឡាយណា ដែលកើតចេញពីការចុះផ្សាយសារព័ត៌មានអំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការជជែកដេញដោលជាសាធារណៈ គួរតែដោះស្រាយដូចមានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ។

- ការដកអភ័យឯកសិទ្ធិសភា ឬការគំរាមដកអភ័យឯកសិទ្ធិនោះ ក្នុងបំណងបំភិតបំភ័យ ធ្វើឲ្យខូចតំលៃដ៏សំខាន់នៃអភ័យឯកសិទ្ធិ ដែលផ្តល់លទ្ធភាពឲ្យមានការពិភាក្សាដោយសេរីអំពីបញ្ហាសាធារណៈ ក្នុងចំណោមតំណាងរាស្ត្រ និងអ្នកធ្វើច្បាប់ ។ ការអនុវត្តន៍បែបនេះគួរតែបញ្ឈប់ ចំពោះការប្តឹងពីការបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ។

- ក្នុងនាមជាអាជ្ញាកណ្តាលឯករាជ្យ និងមិនលំអៀងចំពោះករណីទាំងឡាយដែលនៅចំពោះមុខខ្លួន ចៅក្រមនិងព្រះរាជអាជ្ញា ក៏ដូចជា អង្គការវិជ្ជាជីវៈនានា ដូចជា គណៈមេធាវី មានករណីយកិច្ចមួយខាងវិជ្ជាជីវៈ ត្រូវទទួលយកករណីទាំងអស់ដែលបញ្ជូនមកខ្លួនទៅតាមលំដាប់លំដោយនៃពាក្យបណ្តឹងក្នុងលក្ខណៈត្រឹមត្រូវ ដោយស្មើភាព និងមិនលំអៀង ហើយត្រូវអនុវត្តច្បាប់ដោយគ្មានការរើសអើង ឬបុរេវិនិច្ឆ័យ(សេចក្តីលំអៀង) ។ នេះគឺជាគោលការណ៍ជាសារវន្តមួយនៃយុត្តិធម៌ ដែលមិនគ្រាន់តែដាក់ឲ្យអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែឲ្យឃើញថា ភាគីទាំងអស់ និងសាធារណៈជនទូទៅពិតជាបានអនុវត្តតាម ។

- ក្នុងឆ្នាំ២០០៦ រដ្ឋាភិបាលបានចាត់វិធានការមួយដ៏សំខាន់ក្នុងការដកចេញទោសគុក ជាទណ្ឌកម្មមួយសំរាប់ការបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ ។ ជំហានមួយទៀត ក្នុងការពង្រឹងក្របខ័ណ្ឌច្បាប់សំរាប់ការជជែកដេញដោលបែបប្រជាធិបតេយ្យ នោះគឺការដកបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ចេញពីក្រមព្រហ្មទណ្ឌថ្មីដែលបច្ចុប្បន្នកំពុងដំណើរការព្រាងដើម្បីឲ្យតុលាការរដ្ឋប្បវេណីតែមួយប៉ុណ្ណោះ ដែលមានសមត្ថកិច្ចដោះស្រាយបញ្ហាទាំងនេះ ។ នេះបញ្ជាក់យ៉ាងច្បាស់គ្មានការមន្ទិលសង្ស័យថា ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការសំដែងមតិស្របតាមច្បាប់ និងការទទួលស្គាល់ច្បាស់អំពីតំលៃនៃការជជែកដេញដោលដោយសេរីតាមបែបប្រជាធិបតេយ្យអំពីបញ្ហាដែលជាប្រយោជន៍សាធារណៈ ដែលទន្ទឹមនឹង

នេះដែរ ក៏ត្រូវការពារកិត្តិសព្ទរបស់បុគ្គលឲ្យបានត្រឹមត្រូវ ក្នុងករណីសមស្រប តាមរយៈបណ្ដឹងរដ្ឋប្បវេណីទាមទារសំណង ។

***

## ឧបសម្ព័ន្ធ

**ករណីថ្មីៗនៃបណ្ដឹងបរិហារកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត :**

១. <u>ករណីរបស់លោកស្រី មូ សុខហួរ ប្ដឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងក្រោយមកលោកនាយករដ្ឋមន្ត្រី ក៏បានប្ដឹងប្រឆាំងនឹងលោកស្រី និងមេធាវីរបស់លោកស្រី គឺលោក គង់ សំអុន</u>

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ សមាជិករដ្ឋសភា គណៈបក្ស សម រង្ស៊ី លោកស្រី មូ សុខហួរ បានដាក់ពាក្យបណ្ដឹងមួយប្រឆាំងនឹងនាយករដ្ឋមន្ត្រីពីបទបរិហារកេរ្តិ៍ ចំពោះសន្ទរកថាមួយ ដែលលោកបានធ្វើនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៩ នៅខេត្តកំពត ដែលជាមណ្ឌលបោះឆ្នោតរបស់លោកស្រី ។ នៅក្នុងបណ្ដឹងនោះ លោកស្រី មូ សុខហួរ បានអះអាងថា លោកនាយករដ្ឋមន្ត្រី បានបរិហារកេរ្តិ៍គាត់ ដោយនិយាយសំដៅដល់តំណាងរាស្ត្រស្ត្រីមួយរូបពីខេត្តកំពត ដែលអះអាងថាគាត់បានឱបឧត្តមសេនីយម្នាក់ ដែលក្រោយមកបានចោទថាគាត់របូតឡេវអាវ ។ គាត់ត្រូវបានអះអាងថា ត្រូវគេហៅថា " ជើងខ្លាំង " ដែលជាសំដីប្រមាថមើលងាយជាភាសាខ្មែរ ។ បើទោះជាមិនបាននិយាយចំឈ្មោះគាត់ក្ដី លោកស្រី មូ សុខហួរ អះអាងថា ការនិយាយនេះគឺសំដៅលើរូបគាត់ ។

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ លោកស្រី មូ សុខហួរ និងមេធាវីរបស់គាត់ លោក គង់ សំអុន បានធ្វើសន្និសីទកាសែតមួយនៅទីស្នាក់ការគណៈបក្សរបស់គាត់ នៅរាជធានីភ្នំពេញ ដែលអ្នកស្រីបានប្រកាសអំពីបំណងរបស់គាត់ ក្នុងការដាក់ពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី ។ មេធាវីរបស់គាត់ត្រូវគេរាយការណ៍ថា បានបង្ហាញភស្តុតាង និងមូលហេតុផ្សេងៗ ដែលគាត់អាចប្រើសំរាប់គាំទ្រការចោទប្រកាន់របស់អ្នកស្រី ។

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ មេធាវីរបស់លោកនាយករដ្ឋមន្ត្រី លោក គី តិច បានដាក់ពាក្យបណ្តឹងប្រឆាំងលោកស្រី មូ សុខហួរ ពីបទបរិហារកេរ្តិ៍ ក៏ដូចជា ប្រឆាំងនឹងមេធាវីរបស់លោកស្រី អំពីការបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ដោយការចោទគាត់ថាបរិហារកេរ្តិ៍ខ្លួន ។ លើសពីនេះទៅទៀត លោក គី តិច បានដាក់ពាក្យបណ្តឹងមួយទៀត ប្រឆាំងនឹងលោក គង់ សំអុន ទៅគណៈមេធាវី ដោយអះអាងថាគាត់បានរំលោភលើក្រមសីលធម៌របស់គណៈមេធាវីកម្ពុជា ។

នៅថ្ងៃទី១០ ខែមិថុនា តុលាការក្រុងភ្នំពេញបានតំកល់បណ្តឹងរបស់លោកស្រី មូ សុខហួរ មិនចាត់ការ ។ ករណីបណ្តឹងរបស់លោកនាយករដ្ឋមន្ត្រី ប្រឆាំងនឹងអ្នកស្រី មូ សុខហួរ និងមេធាវីរបស់អ្នកស្រី នៅតែបន្តចាត់ការយ៉ាងសកម្ម ព្រមជាមួយនឹងការគំរាមដកអភ័យឯកសិទ្ធិសភាពីអ្នកស្រី ។ គណៈមេធាវីក៏បានចាប់ផ្តើមធ្វើការស៊ើបអង្កេតការចោទប្រកាន់ពីបទបំពាន លើក្រមសីលធម៌របស់លោក គង់ សំអុន ផងដែរ ។

២. <u>បណ្តឹងពីបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ប្រឆាំងនឹងលោក ហង្ស ចក្រា និពន្ធនាយកនៃកាសែត *ខ្មែរម្ចាស់ស្រុក*</u> ៖

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ តុលាការក្រុងភ្នំពេញបានចេញដីកាកោះហៅ លោក ហង្ស ចក្រា និពន្ធនាយកនៃកាសែត *ខ្មែរម្ចាស់ស្រុក* មកបង្ហាញខ្លួននៅចំពោះមុខតុលាការនៅថ្ងៃទី៣ ដើម្បីសាកសួរអំពីបណ្តឹងលើរូបគាត់ពីបទបរិហារកេរ្តិ៍ និងការញុះញង់ ដោយមេធាវីរបស់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ។ បណ្តឹងនេះ ត្រូវបានគេរាយការណ៍ថា ទាក់ទងនឹងអត្ថបទមួយចំនួនដែលបានចុះផ្សាយនៅថ្ងៃទី៥ និងទី៧ ខែមេសា និងថ្ងៃទី២១ ខែឧសភា លើ

ទំព័រកាសែត ដែលលាតត្រដាងពីអំពើពុករលួយរបស់មន្ត្រីមួយចំនួនដែលធ្វើការជាមួយលោក សុខ អាន ។ (អត្ថបទមួយមានចំណងជើងថា " ហ៊ុន សែន បានបង្រ្កាបមន្ត្រីខិលខូច និងមន្ត្រីពុករលួយដែលនៅជុំវិញលោក សុខ អាន ") ។ បណ្តឹងនេះ ត្រូវបានគេរាយការណ៍ថា អះអាងថាការចុះផ្សាយអត្ថបទទាំងនេះ នាំឲ្យប៉ះពាល់ដល់ស្ថិរភាពនយោបាយ ដោយសារអត្ថបទនេះសរសេរអំពីមេដឹកនាំរដ្ឋាភិបាល ។ លោក ចក្រា បានមានប្រសាសន៍ថា ព្រះរាជអាជ្ញារង លោក សុខ រឿន បានសាកសួរគាត់អំពីប្រភពព័ត៌មាននៅលើអត្ថបទសារព័ត៌មានរបស់គាត់ ប៉ុន្តែលោក ចក្រា មិនព្រមបញ្ចេញឲ្យដឹង ។ មាត្រា២ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ អនុញ្ញាតឲ្យអ្នកសារព័ត៌មានការពារអត្តសញ្ញាណនៃប្រភពព័ត៌មានរបស់ខ្លួន ។

៣. <u>បណ្តឹងពីបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិតប្រឆាំងនឹងលោក មឿន សុន ប្រធានអង្គការមូលនីធិអរិយធម៌ខ្មែរ</u> ៖

នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៩ មេធាវីរបស់រដ្ឋាភិបាល លោក ប៉ុល ចាន់ដារ៉ា បានដាក់ពាក្យបណ្តឹងមួយពីបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ទៅតុលាការក្រុងភ្នំពេញប្រឆាំងនឹងលោក មឿន សុន ប្រធានមូលនីធិអរិយធម៌ខ្មែរ ដោយចោទថាគាត់បានចុះផ្សាយព័ត៌មានមិនពិតទាក់ទងនឹងការចាប់ដំឡើងអំពូលភ្លើងនៅប្រាសាទអង្គរវត្ត ដោយអះអាងថាកំដៅពីអំពូលភ្លើងទាំងនោះនឹងធ្វើឲ្យខូចខាតដល់ជញ្ជាំងប្រាសាទ ។ មេធាវីរដ្ឋាភិបាលបានចោទប្រកាន់ លោក មឿន សុន ថាប្រើប្រាស់ពាក្យសំដីនេះបរិហារកេរ្តិ៍ដល់រដ្ឋាភិបាល និងញុះញង់ឲ្យមនុស្សរាល់គ្នាសំឡឹងមើលរដ្ឋាភិបាលក្នុងផ្លូវអវិជ្ជមាន ។

៤. <u>បណ្តឹងពីបទបរិហារកេរ្តិ៍ ដោយលោកអភិបាលក្រុង កែប ជុតិមា ប្រឆាំងនឹង លោក សម រង្ស៊ី</u> ៖

អភិបាលរាជធានីភ្នំពេញ លោក កែប ជុតិមា បានដាក់ពាក្យបណ្តឹងមួយនៅថ្ងៃទី២៧ ខែឧសភា ទាក់ទងនឹងសន្ទរកថារបស់លោក សម រង្ស៊ី ត្រូវបានគេរាយការណ៍ថា បានធ្វើនៅថ្ងៃទី១៤ ខែឧសភា ដែលក្នុងនោះគាត់បានអះអាងថា លោក កែប ជុតិមា ពាក់ព័ន្ធនឹងការទិញសន្លឹកឆ្នោតសំរាប់គណៈបក្សប្រជាជន នៅមុនការបោះឆ្នោតក្រុមប្រឹក្សាខេត្ត-ក្រុង ថ្ងៃទី១៧

ខែឧសភា ។ រហូតមកទល់ពេលនេះ លោក សម រង្ស៊ី មិនទាន់ត្រូវបានតុលាការកោះហៅមកសាកសួរនៅឡើយទេ ។

៥. <u>បណ្តឹងពីបទញុះញុង និងបទបរិហារកេរ្តិ៍ ប្រឆាំងនឹងលោក ហូ វ៉ាន់ សមាជិករដ្ឋសភាគណៈបក្ស សម រង្ស៊ី</u> ៖

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ លោក ហូ វ៉ាន់ សមាជិករដ្ឋសភាគណ: បក្ស សម រង្ស៊ី ត្រូវបានតុលាការក្រុងភ្នំពេញកោះហៅ តាមបណ្តឹងមួយពីបទញុះញុង និងការបរិហារកេរ្តិ៍ប្រឆាំងនឹងរូបលោក នៅថ្ងៃទី២៧ ខែមេសា ដោយមន្ត្រីកងយោធពលខេមរភូមិន្ទចំនួន ២២ រូប ដែលបានជំទាស់នឹងបទអត្ថាធិប្បាយរបស់លោក ហូ វ៉ាន់ អំពីសញ្ញាប័ត្រថ្នាក់ក្រោយឧត្តមសិក្សា ដែលបានប្រគល់ជូនមន្ត្រីនៃកងយោធពលខេមរភូមិន្ទមួយចំនួន ដោយស្ថាប័នយោធាវៀតណាមក្នុងខែមេសា ។

៦. <u>ប្រធានសមាគមយុវជននៃគណៈបក្ស សម រង្ស៊ី មួយរូប ត្រូវបានតុលាការសំរេចឲ្យបង់ប្រាក់ពិន័យចំនួន ១២៥០ ដុល្លារ ពីបទបរិហារកេរ្តិ៍</u> ៖

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៩ លោក សួង សោភ័ណ្ឌ អាយុ ២២ ឆ្នាំ ជានិស្សិតច្បាប់ និងជាប្រធានសមាគមយុវជននៃគណៈបក្ស សម រង្ស៊ី ថ្នាក់មូលដ្ឋាន ត្រូវបានចោទប្រកាន់ និងចាប់ខ្លួន និងផ្តន្ទាទោសពីបទបរិហារកេរ្តិ៍នៅក្នុងអំឡុងពេលបីថ្ងៃ និងពិន័យជាប្រាក់ ៥ លានរៀល ដោយសារគាត់បានបានសរសេរពាក្យសំដីរិះគន់រដ្ឋាភិបាលនៅលើជញ្ជាំងផ្ទះគាត់ ។ លោក សួង សោភ័ណ្ឌ គឺជាសមាជិកម្នាក់នៃគ្រួសារមួយ ក្នុងចំណោមប្រជាពលរដ្ឋរាប់រយគ្រួសារ ដែលបានតវ៉ាជាមួយក្រុមហ៊ុនស៊ូកាគូ និងសាលាក្រុង ដើម្បីការពារសិទ្ធិលើដីធ្លីផ្ទះសម្បែងរបស់ខ្លួនក្នុងករណីជំលោះដីធ្លីនៅបឹងកក់ ដែលមានប្រជាពលរដ្ឋ៤០០០ គ្រួសារកំពុងស្ថិតក្នុងការគំរាមបណ្តេញចេញ ។

***